# សទ្ទានុក្រមនៃពាក្យខ្លះក្នុងកំណាព្យ "ល្បើករអង្គរវត្ត"

ដោយ សុខា ផ្ទុម និង ហម ឆាយលី

ពាក្យបំព្រួញដែលប្រើក្នុងសទានុក្រមនេះ :

ពាក្យសំស្ក្រឹត (សំ.), ពាក្យបាលី (បា.), ពាក្យខ្មែរចាស់ (ខ.ច.), ពាក្យខ្មែរ (ខ.) មើលពាក្យ (ម.ព.)... ។

## ក

កវងរជា : ? ។

កក្វាត់ (ខ.) : ? ។ (ក្វាត់ : ស្ទាក់ផ្លូវ, រារាំងមុខ, ស្កាត់, ក្វាត់ចោរ) ។

កក្លាក់សែម : ?

កវើក (ខ.) : សត្វស្វាបមួយប្រភេទ, ពពួកប្រវើក (កវើក-កវែក) ប្រវែក ។

កន្ទៀង (ខ.) : ? ។

កម៉ាំងកណ៌ា : ? ។

ក្ទម្ព (សំ) : ដើមស្រដៀងដើមត្រកែងទួយនិងផ្កាស្រដៀងផ្កាថ្កូវ តែតូចជាងបន្តិច ។

កញ្ជ្រីល (ខ.) : -ក្បាច់ចម្លាក់មានលំនាំជាវល្លិ៍, -គ្រឿងអលង្ការ ។ -ឈ្មោះវល្លិ៍មួយប្រភេទ វល្លិ៍កញ្ជ្រីល ។ -ឈ្មោះរោគសើរស្បែក "កញ្ជ្រីល", កើតកញ្ជ្រីល ។

កម្ពណ្ឌ : ឈ្មោះក្រុងយក្ស អ្នកត្រួតត្រាទ្វីបបក្ខពួកខាងរាពណ៍ ។

កាភារ : (៣៨១) () ? ។

កាលប្បព្រឹក្ស (សំ.) : រុក្ខជាតិដែលមានអាយុរាប់កប្បនៅស្ថានសួគ៌ ។

កាកែស : ? (ការកេស (ខ.ទ.) : ផ្កាមួយប្រភេទ ?) ។

កាមពាលី : ឈ្មោះយក្សមួយដែលត្រូវជាក្មួយក្រុងរាពណ៍ ។

កាលសូត្រ (សំ.) : ឈ្មោះស្ថាននរកទី២ ។

កុម្ភកទាធរ : មេយក្សកាន់មោងកស្ស័កធំដូចកុម្ភកាណ៌ដែរ វាត្រូវមេទ័ពស្វាឈ្មោះ យុទនិល សម្លាប់ ។

កុម្ភកាណ៌ : ឈ្មោះយក្សប្អូនរបស់រាពណ៍ ។ វាមានមេទ័ពឈ្មោះធរមាក្ខដែលចាប់សុគ្រីពបាន។ វាដេករហូតលុះត្រាតែចេញច្បាំងទើបក្រោកម្តងៗ ។ ចុងបំផុត ត្រូវព្រះលក្ស្មណ៍សម្លាប់ ។

ក្ខខាន់ : មហាព្រាននៃព្រៃដែលបំរើព្រះរាម, ព្រះលក្ស្មណ៍ម្តងម្កាល ។

កេតុមាលា : (កេតុ : រស្មីពិលើមេឃ,

+មាលា : កម្រង), កម្រងរស្មីអំពីលើមេឃ ។
កៃ (ខ.) : ? ។
កៃកាកៃស (ខ.) : ? ។
កៃក្រាយ (ខ.) : ឃរាំកាច់រាង ។
កៃមលាយ : ? ។
កៃលេន : ? ។
កៃលាស : ស្ថានព្រះឥសូរ ។
កៃសើន (ខ.): ខ្មែរហៅជនជាតិអាណ្ណាមថា កៃសឹន ។
កៃសែន : (៥០៦) ? ។
កោសី (បា.) : ព្រះឥន្ទ្រ ។
កៅទណ្ឌ : ធ្នូ ។
កំនើង (ខ.) : ? ។
កំឃ្មរ (ខ.) : ? ។
កាំ (ខ.) : ព្រួញ, សរ ?
កាំពាលី : ព្រួញរបស់ពាលី ដែលសម្លាប់ ហ្វុលចក្ខុ ។
ក្ដារបែន (ខ.): បន្ទះក្ដារ ឬ ក្ដារជឿ ?
ក្រវើន (ខ.) : ឧស្សាហ៍, ដាសតឿន, ខំ ប្រឹងប្រែង ។
ក្រឡាច័ន្ទ : ? ។
ក្រិត្តិយុគ (បា.) : ជាស្ថាននរក ? ។
ក្រិតាយុគ (កឬតាយុគ) : យុគទី១នៃផែន ដី ។
ក្រមុទ : (៨២) (គួរប្រើកុមុទវិញ) (សំ.?) : ជាឈ្មោះផ្កាមួយប្រភេទ នៅក្នុងទឹក្ត ផ្កាឈូក ក្រហម ។
ក្របិទ្ធកេសរ : អ្នកសម្លាប់ទសមុខ ។
ក្រួយក្រួល : ? ។
ក្រុងខរ : ឈ្មោះក្រុងយក្សមួយអង្គ ដែលត្រូវ ជាប្អូនរាពណ៍, សោយរាជ្យនៅក្នុងព្រៃទណ្ឌ ការ មានក្ខួនឈ្មោះត្រីមុខ និងប្អូនឈ្មោះ ក្រុង ទុសៈ ។
ក្រអូបហ្វង់ : (៧០) ក្រអូបឈ្ងុំ ក្រអូប ឈ្ងុក ឈ្ងង ។
ក្រួយក្រោល : ? ។
ក្រទា : ក្រោកដើរតេងតាង, ដើរព័ទ្ធវង់នៅ ជិត។ (មើលពាក្យ ក្រទីក្រទា ទៀតផង) ។
ក្បាលពេជ្រសម្រេច : ? ។
ក្អក់ពេជ្រ : ដំបូលប្រាសាទ ? ។ (ក្អក់ចិត្ត : អាក់អន់ចិត្ត, អាក់អន់ព្រះទ័យ) ។
ក្ដាំងងា : ឈ្មោះឈើមួយប្រភេទ មានផ្កា ក្រអូប គ្របកផ្កាវែង ។
ក្ញាប់ក្ញាយ, ខ្ញាប់ក្ញាយ : ក្រឡប់ក្ញាយ, ក្រឡាប់ក្ញាយ ? (ក្ញាយ : មិនសុទ្ធ, ប្រែ ប្រួល) ។



ខ

ខុននិល (ខុន្និល) : ជាសត្វស្វាដែលបាន សម្លាប់យក្ស ឈ្មោះមុខរក្ខសៈ ? ។
ខ្ទឹង : រុក្ខជាតិមួយប្រភេទ សម្បក និងស្លឹក ប្រហែលគ្នានិងសុរភី ដែលមានផ្កាពណ៌ស ហើយក្រអូប, ផ្កាព្រៃ ។
ខៀន (ខ.) : សំពត់កប្បាសពោះពុម្ពក្រាស។ ជាផ្កាសម្រាប់ស្លៀកចងក្បិន ។
ខ្សិនមន្តរ : ?
ខៀនកាសា : ខៀនមានផ្កាជាផ្កាច័ន្ទជានិច្ច ទោះពណ៌អ្វី ក្រឡាប៉ុន្មានក៏ដោយ ។
ខែក (ខ.) : ស្គរថ្វា, ស្គរមួយប្រភេទដែល មានរាងស្មើ ដាសស្បែកទាំងពីរខាង (ទីនេះ ហៅសំដៅជនជាតិថ្វា ?) ។ សូមអានពាក្យ ភ្លេងក្ងងខែក ទៀតផង ។
ខែក, ក្វលា, យៀ (ខ.) : (ខែក : ជនជាតិ ថ្វា, ក្វលា : កូឡាប៉ៃលិន, យៀ : ជនជាតិមន អម្បូរខ្មែរដែរ) ។
ខ្នាន់ខ្មី : ? ។ -ខ្នាន់: ពពួកក្រុមពលទាហាន កាន់ធ្នូ ។ -ជាងកោរកាត់ព្រះកេសា ។ -ត្រី ម៉្យាងហៅថា ត្រីខ្នាន់ ។
ខ្សិនមន្តរ : (៣៨១) ? ។ សូមអានពាក្យ ក្សិណ (សំ.), ខណៈ (បា.) ពេលនោះ ។

គ

គណនា : រៀបរាប់, អត្ថាធិប្បាយ ។
គន្ធព្វ : ទេវតាពពួកក្រុមជន្ត្រី-របាំនៅឋាន ត្រៃត្រឹង្សា ។
គន្ធមាទបរពត (បព៌ត) : ភ្នំគន្ធមាទ ?
គវ្លិស្ស-ក្វលី : ម្រាមដៃ ។
គាងឃ្វាយ-គាងគ្វាយ (សំ.) : ជាចម្លាក់ មួយបែប នៃប្រាសាទបូរាណ, ត្រីសូលិគាង ឃ្វាយ ។
គុជ-គុជា : ដំរី ។
គ្រឿងសហ័ស្ស : (គ្រឿង : សម្ភារៈ + សហ័ស្ស, ១០០០) : គ្រឿងអាវុធ ១.០០០ ។
គោតគោះ : (គោត : មេហ្វូង, មេខ្លាង + គោះ : ដំតិចៗ) : ស្គរជាមេគេដែលដឹកនាំ ប្រគុំ ហើយគោះតិចៗ ។ សូមអានពាក្យគោត្ត (បា.), គោត្រ (សំ.) ទៀតផង ។

----------

ច

ចរណី : ?
ចតុរស : (៤៧៦) បួនជ្រុង ? ។
ចតុលោកបាល : ស្ដេចទេវតាទាំង៤អង្គ ជា អ្នករក្សាលោកទាំង៤ទិស គឺ : ព្រះបាទ ធតរដ្ឋ រក្សាទិសខាងកើត ។ ព្រះបាទ វិរុឡ្ហកៈរក្សា

ទិសខាងត្បូង ។ ព្រះបាទ វិរូបក្ខ រក្សាទិសខាងលិច ។ ព្រះបាទ កុវេរៈ រក្សាទិសខាងជើង ។ ទេវតាដែលរក្សាទិសទាំងបួននៃផែនដី ។

ចំនួ : ដើមឫចខ្នឹមបារាំង, ផ្កាជារួតវែងៗ ។

ចក្រិន្ទ (ចក្រ+ឥន្ទ្រ): ព្រះឥន្ទ្រាធិរាជ? ។

ចក្ខិន្ទ ឬ ចក្ខុន្ទ្រីយ : (៩៣) (ឥន្ទ្រិយ, គឺភ្នែក) អ្នកដែលមានភ្នែកជាធំ, អ្នកដែលមានភ្នែកទិព្វ, ភ្នែកមានភ្នាក់ងារជាធំខាងការរំពឹងឃើញ ។

ចំនួឆាយា : រោងល្ខោន, រោងគសាលសម្រាប់ស្តេច ។

ចាមរី-ចាមរា : សត្វចតុបាតប្រភេទក្របីមាណតូចជាងក្របី តែមានរោមវែងស្រោចស្របខ្លួន ច្រើនរស់នៅតំបន់ត្រជាក់, ទីបេត៍ ...។

ចាម្រា-ចាម្រី : សេះបង្កង់ ។

ចុត (ខ.) : ធុច, អាក់ ។

ចំអេង (ខ.) : អវយវៈនៃសត្វស្លាប, ស្លឹងស្លាប ។ ចំអេងក្លម, ចំអេងឆ្នាំង ។

ចោក្ខចាក្ខសេនា : ? ។

ចោម (ខ.) : អានថា "ចម", មេ, កំពូលខ្ពស់, ចុងកំពស់, ចោមចក្រ ។

ចោមត្រៃ : ជាកំពូលលើលោកទាំងបី : -ស្ថានសួគ៌, -ស្ថានលើដី, -ស្ថានក្រោមដី ។

ចោម : ព័ទ្ធ ចោមរោមចាប់ ។

ច្រវាល : កងដែកភ្ជាប់គ្នាជាមួយច្រវាក់ ។

ច្រវាលច្រវាក់ : កងដែក និង ច្រវាក់ សម្រាប់ដាក់អ្នកទោស ។

----------

ឆ

ឆ័ត្ររួត : របស់ដែលសម្រាប់ការពារកំដៅ ឬ ទឹកភ្លៀងដើម្បីការពារព្រះ, ព្រះមហាក្សត្រិយ៍ ។ ឆ័ត្រដែលមានច្រើនជាន់, ខ្ពស់ស្រួច ។

ឆ្ងៅ (ខ.) : ល្អ, ស្អាត, ស្រងៅ (ប្រើក្នុងកំណាព្យ) ។

----------

ជ

ជតាយុ : ឈ្មោះគ្រុឌ ជាមិត្តភក្តិរបស់ព្រះបាទ ទសរថ ជាបិតារបស់រាម ឬ សត្វឥន្ទ្រីដែលកាងស្លាបងងឹតដី ដើម្បីការពារកុំឲ្យរាពណ៍ហោះយកនាងសីតាទៅបាន ។ ប៉ុន្តែ ត្រូវបាក់ស្លាបដោយសារព្រះទម្រង់ របស់ក្រុងរាពណ៍ ។

ជិទេព-បិតរៈ : ព្រះវិញ្ញាណក្ខន្ធនៃអតីត ព្រះមហាក្សត្រិយ៍, ជីដូនជីតា ឬ បុព្វការីនៃយើងគ្រប់ៗគ្នា ។



ជនក : ព្រះជនក ជាក្សត្រិយ៍គ្រងរាជ្យ នៅនគរមួយឈ្មោះ, ក្រុងមិថិលា ។ ជាបិតាចិញ្ចឹមរបស់នាង សីតា ។

ជម្ពូវនរនាថ : (ជម្ពូ + វនរនាថ) ? ។

ជំពូពានរ : ជាស្តេចស្វាព្រាហ្ម ត្រូវជាត្រូហោរានៃព្រះរាម ។

ជាងជៅ (ខ.) : ជាងអ្នកដាប់ ឬអ្នកលកសាច់ឈើ (ថ្មដែរឬ ?) ។

ជ្រោមជ្រួត (ខ.) : ជ្រោមជ្រែង, ជ្រួតជែគ្នា ។

----------

ឈ

ឈូកសែត (បា.) : ហៅក្លាយពីពាក្យបាលីឈូកសែត្ត ឈូកស ។

----------

ដ

ដរាកាយ : (៩៣) ? ។

ដកចំនួ : ផ្កាច័ន្ទ (ទំនងជាពាក្យខ្មែរដែលសៀម ខ្ចីយកទៅប្រើ, នៅស.វ.ទី១៦-១៧ ពាក្យនេះ ត្រឡប់ចូលមកខ្មែរវិញ) ។

ដងក្តារជវា(ជហ្វា): ក្បាច់គាក់តែងលំអផ្នែកពពួកដំបូល,ផ្ទះ, ប្រាសាទ, សាលា, វិមាន, អាគារធំៗ ។

ដងបង្ហូរ : ប្រដាប់បង្ហូរទឹក, ប្រេង ឬ ស្រា ឬមាត់ចំពួយ ។

ដាសជាចលនា : (៤៦៨) ? ។ ពាសមាស, បិតមាស ។ ដាសមាត់ (ខ.) : បិទមាត់, ដាសស្តរ, ពាសស្តរ ។

ដាបនរក (សំ, បា.) : ឋាននរកទី៦ ។

ដាវឿង (ខ.) : ស្បៃរឿង ។

ដុងដោម (ខ.) : ចុងឈើខ្ពស់, កំពូលខ្ពស់ស្រួច, ខ្ពស់ត្រដែត, ត្រដឹម, ថ្ងៃថ្នូរ, ប្រសើរ។

ដើរទេសពនេចរ(ខ.) : (ដើរទេស : ដើរពីប្រទេសមួយ ទៅប្រទេសមួយ, ពីតំបន់មួយទៅដំបន់មួយ, ពីស្រុកមួយ ទៅស្រុកមួយទៀត, (ឧ. អ្នកដើរទេស + ពនេចរ : អ្នកធ្វើដំណើរតាមព្រៃ) : អ្នកដំណើរតាមស្រុកតាមព្រៃ ។

ដោម (ខ.) : ខ្ពស់ ។

ដំបូចផ្តោះផ្តង (ខ.) : សំដីឡេបខាយ, សំដីដាក់ផងដាក់ផ្ទៃ, សំដីទ្រគោះបោះបោក, មាក់ងាយ ? ។

----------

ត

តិលកាល៏ា-តិលកាលៈ ពេលវេលាដ៏ល្អ ។

ត្បិសិង្គា : ? ៣៨៣ ។

ត្រនង់ : ប្រញាប់ ? ។

ត្រឡែងកែង : (១១៦) ? ។

ត្រឡាំង (ព.ខ) : ខ្លាំង្គ ពូកែ ខ្លាំងខ្លា ។ ឧ. កម្លោះត្រឡាំង្គ ប្រុសត្រឡាំង ។

ត្រីស្វល័ : ព្រះខ័នផ្ទៃបី ។

ត្រីកូត : ភ្នំ ? ។

ត្រីសិរ : ឈ្មោះក្រុងយក្សមួយអង្គ ជាកូនក្រុងរាពណ៍ ដែលព្រះរាមចង់បាញ់សម្លាប់តែត្រូវពិភេកសុំឃាត់ ។ ទីបំផុត ត្រូវហនុមានសម្លាប់បាន ។

ត្រិភេទ-ត្រៃវេទ : កំពីទាំងបី នៃព្រហ្មញ្ញសាសនា ។

----------

ទ

ទសមុខ-ទសកណ្ឋ-ទសភក្ត្រ : ជាឈ្មោះមួយទៀតនៃក្រុងរាពណ៍ ។

ទសផែន : ឈ្មោះក្រុងយក្សមួយអង្គ ។

ទងវង : ទន់ភ្លន់, ល្វាសល្វន់,ល្វតល្វៃ ។

ទង់ជ័យល្បំ : ទង់ជ័យបក់រវិចជាច្រើន ។

ទល្លរ : ? ។ ទល្លរនាងប្រាល (ចាំងប្រាល ?) ។

ទិព្វទេពទេវា : គ្រួសារនៃពាក្យទេព ។

ទេវីពន្និតា : មហេសី, ភរិយាជាទីស្រឡាញ់ ។

ទុរមុខ : មេទ័ពយក្ស ដែលត្រូវមេទ័ពស្វាឈ្មោះកេសរសម្លាប់ ។

ទូភី : ឈ្មោះក្របីមួយខ្លាំងពូកែ ដែលត្រូវស្តេចស្វាឈ្មោះពាលីសម្លាប់ ។

ទៀប : ក្បែរ, ជិតៗ, រៀងអាយ, នាយអាយ។

ទំពួន : ជនជាតិមន-ខ្មែរ ។

ទេពារក្ស(ទេព+អារក្ស)-ទេពព្រក្ស-ទេព្រក្ស : ទេវតាអ្នកចាំយាម, យាមរក្សាព្រៃ, អ្នករក្សាលោក, រក្សាមនុស្ស...។

ទ្រទេសទ្រទន់ : ញៀងញ៉ង, ទន់ភ្លន់, ល្វាសល្វន់, ល្វតល្វៃ ។

ទ្រាយសី : ? ។ ទ្រាយ : -គ្រឿងរទេះគោរទេះក្របី, ទ្រាយរទេះ ។ -ឈ្មោះម្រឹគពពួកឈ្លូស ។

ទ្រើស : ធំ ត្រគោះ ។ ទ្រើសឈ្លង : កាចខ្លាំង, ចិត្តអាក្រក់, សាហាវយង់ឃ្នង ។

----------

ធ

ធ្យាន, ឈាន : ការយល់ដឹងខាងផ្លូវធម៌ ។

ធ្លូទូន (ធ្លូមន, ធ្លូខ្មែក) : ឈ្មោះធ្លូមួយប្រភេទ ។

----------

ន



នរកឧសភៈ : ជាឋាននរកមួយក្នុងចំណោមឋាននរកឯទៀត (ដូចជា : ១-សញ្ជិតមហានរក, ២-កាលសូត្រមហានរក, ៣-សង្ឃាដមហានរក, ៤-រោរពនរក, ៥-រោរពមហានរក, ៦-តាបនរក, ៧-មហាតាបនរក, ៨-មហាអវិចី...) ។

នរិន្ទ្រ (នរ+ឥន្ទ្រ)-នរិន្ទ : បរិវារនៃព្រះឥន្ទ្រ, ដែលខ្ពង់ខ្ពស់, ដែលប្រសើរលើសលប់, ក្សត្រិយ៍គ្រងរាជ្យ ។

នរទី : ស្ទឹង, ទន្លេធំ ។

នន្ទ+ឧទ្យាន : សួនច្បារបស់ព្រះឥន្ទ្រ, សួនច្បារដែលជាទីរីករាយ, កំសាន្ត ។

នាឡូនា : (៣៨១) ? ។

និលបុល : (៨១) ? ។ ផ្កានិលបុល ?

និមិន្ទរ : (៤៤១) ? ។

និល (សំ) : ពណ៌ខ្មៅ, ត្បូងដែលមានពណ៌ខ្មៅ ។ និលបុល : ប្រលិតពណ៌ស្វាយ, ពណ៌ស្វាយចាស់, ស្វាយក្រមៅ ។

នី : -ពោរពេញ, ពាសពេញទៅដោយ ។ -រុក្ខជាតិមួយប្រភេទ ដុះនៅព្រៃភ្នំ ដើមខ្ពស់ស្រដៀងនិងដើមស្រឡៅ, ដើមនី ។

នព្វរតន៍ : (៤២៥) ? ។

នុភី-នភី-នភា : អាកាស ។

នូនស្រី : រុក្ខជាតិតូចៗមានផ្កាដូចកណ្តឹងពណ៌សមានក្លិនក្រអូបសាយ ។

----------

ប

បវរ : ប្រសើរ, ថ្លៃថ្នូ ។

បន្ទា : ក្បាច់ដំបូលប្រាសាទ ។

បណក្ខា : ? ។

បល្ល័ង្កទ្រាប់ខ្សាច់ : ? ។

បង្ករ : ? ។ សូមមើលពាក្យ ផង បង្ករទៀតផង ។

បរិឆាត់ : ដើមរលួសខ្មែរ ? ។

បរិបាល : ការអភិបាលមើល, ត្រួតត្រាដោយជុំវិញ ។

បង្គប្ប-ស្បង់កាច់ : ? ។ សូមអានពាក្យសត្ត ស្បង់កាច់ ទៀតផង ។

បពេជ្ជឥទ្ធវ : (១៣៧) យើងរក្សាទុកអត្ថភាវិរុទ្ធដើម ? ។ ពុំដឹងសរសេរដូចម្តេច ហើយពុំយល់ន័យទៀតផង ។ (ម.ព.) ឥទ្ធវ ទៀតផង ។

បាកាន : កំពូលដីមានក្បូរក្បាច់ ។

បារាំង : សម័យខ្មែរកណ្តាល (ស.គ.ទី ១៤ ដល់ ១៨) ខ្មែរហៅសំដៅជនជាតិ "ព័រទុយហ្គេ" ។

បូទុមព្រាក់ : ? ។
បូញាប់ : ផ្កាមួយប្រភេទ ? ។
ប្រជី, ប្រជីពរ, ប្រជ្បី, ប្រជ្បីពរ : ? ប្រុះ : ភ្ញីប្រុះ, ភ្ញីព្រោងព្រាយ, ដែលភ្ញីចម្រុះពណ៌ផ្កា ។
ប្រជីយក្ស : ? ។
ប្រជីយុត (-ប្រតិយុទ្ធ) : ? ។
ប្រត្តិរុទ្ធ : ? ។
ប្រត្យក្ស (សំ.) : ពិត, ប្រាកដ ។
ប្រវិណ្ណ (មកពីពាក្យ វិណ្ណ) : ចងជាច្រើនជុំ, វិណ្ណចុះ វិណ្ណឡើង, ចងព័ទ្ធ ។
ប្រវាល-ប្រពាល (សំ.) : ឈ្មោះរតនៈ, ឈ្មោះត្បូងមួយត្រភេទ, កែវប្រពាល ។ -ប្រវាល (ខ.) : ទីវាល, ទីវាលធំធេង, លាតសន្ធឹងលន្លោច, ប្រវាលសាគរ) ។

----------

ផ

ផាយ : លឿនយ៉ាងខ្លាំង, សេះផាយ, ខ្យល់ផាយផាត់, បំបោលសេះ, បញ្ឆេរធ្វើឲ្យសត្វរត់លឿនទៅមុខ។ ម.ព. បំផាយទៀតផង។
ផ្ទុល : ដើមឈើមួយប្រភេទ ដែលមានផ្កាក្លិនក្រអូប ។
ផ្កាក់ : ឈ្មោះគ្រឿងសស្ត្រាវុធមួយប្រភេទធ្វើអំពីដែក, កាំបិតមានផ្ទៃវែង ដងវែង សម្រាប់កាប់ឆ្ការព្រៃ ឬ កាប់អ្វីៗបាន ។
ផ្ទះរូត : ផ្ទះដំបូលតម្រូត ។
ផ្ទាញ, បំផ្ទាញ : ផ្ទាញ់ ។
ផ្លូក (ខ.) : ទឹក, វព្លក, គិតផល់, អាលោះអាល័យ, ភ្នកទឹក ។
ផ្តែរ : ទទឹងទ្វារពីខាងលើ, ចម្លាក់លំអរពីខាងលើទ្វារចូលប្រាសាទ, ទ្វារព្រះវិហារ ឬទ្វារបញ្ជោត ។ ផ្តែរផ្ទាស-ផ្តែរផ្ទះ ? ។

----------

ព

ពពាល : -ពណ៌សឆ្នកលាយជាមួយពណ៌ឯទៀត, គោពពាល ។ ម.ព. ពពាលខៃ (ជារុក្ខជាតិម្យ៉ាង) ទៀតផង ។
ពរស្តាពរ : (៩០២) ? ។
ពាឲ្យ : ស្តរធំ, ពាឲ្យគងហ្ងទុក ។
ពាន-ពារ : ឡើងរំលង, ឡើងពាររំលោភលើ។ ម.ព. ពានគ្រោក ពានទ្រាំង ទៀតផង។
ពាណឹង : ? ។
ពាជី : សេះ ។
ពាលី : ស្តេចស្វាមួយអង្គ ជាបុត្រព្រះឥន្ទ្រដែលបានផ្ចាញ់ទូភីស្តេចក្របី ។
ពាធា (សំ.) : បៀតបៀន, គ្របសង្កត់,



សម្ងាប់, អំពើពាធា ។
ពិទាយ : ឈ្មោះកែវ ឬ ត្បូងដីមានដំឡៃម្យ៉ាងដែលមានពណ៌ក្រហមខ្ចី កែវពិទាយ ។
ពិណា-វិណា (សំ.) : ជាចាប៉ីម្យ៉ាង ។
ពិភេក : ជាឈ្មោះក្រុងយក្ស, ចេះស្ទាត់ជំនាញផ្នែកវិជ្ជាហោរាសាស្ត្រ, ជាហោរារបស់ក្រុងរាពណ៍ (ពិភេក ត្រូវជាប្អូន របស់ក្រុងរាពណ៍ ។ ប៉ុន្តែ ត្រូវក្រុងរាពណ៍បណ្តេញចេញហើយក៏សុំជ្រកកោនរស់នៅជាមួយព្រះរាមវិញ) ។
ពិស្ណុការ-ព្រះពិស្ណុការ : ជាពាក្យដែលខ្មែរប្រើតាំង ពីស.វ.ទី១៤ ជាមេជាងខាងស្ថាបត្យកម្មនៅស្ថានសួគ៌ គឺ វិស្វកម្មទេវបុត្រ ។
ពិទូរ្យ-វៃទូរ្យ (សំ.) : ពេជ្រភ្នែកឆ្មា ។
ពិទ្រុម : កែវប្រពាល, កែវពិទ្រុម ។
ពុទ្ធជាតិ : ឈ្មោះឈើមួយប្រភេទ មានសណ្ឋានដូចវល្លិ៍ មានក្លិនក្រអូបឆ្អិត, ផ្កាពុទ្ធជាតិ (សៀមអានថា ពុទ្ធឆាត) ។
ពុទ្ធលេ-ពុតធ្លេ-ពោធិ៍ធ្លេ : ឈ្មោះប្រទាលមួយប្រភេទមានស្លឹក និងដើមដូចចេកទេស។
ពុងពោះ-ពោះពុង : (ពុង : ពោះវៀន) ពោះ និងពោះវៀន ។
ពេជ្រយ័ន្តរថ : រាជរថកើតសម្រាប់ព្រះឥន្ទ្រ រថពេជ្រយ័ន្ត ដែលមានរចនាដោយត្បូងពេជ្រ រត្នៈព្រោងព្រាយ ។
ព្យោមាអាកាស : ពពក, ខ្យល់, អាកាស, មេឃ ។
ព្រត : ការបួសជាឥសី, សាងផ្នួស, ការតាំងសីល, តាំងមន្ត, ដំឡើងតបះ ។
ព្រហ្មាស-ព្រហ្មាស្ត្រ: កូនសររបស់ព្រះរាម។
ព្យូហ៍ : ទ័ព, កងទ័ព ។
ពះ : ផ្ទាប់ខ្លួន និងខ្លួន, តទល់ជាប់ខ្លួន និងខ្លួន, ជួបប្រទះ ។

----------

ភ

ភគទេស : ឈ្មោះក្រុងយក្ស ។
ភមរាកាឡី : (១៧៤) ? ។
ភាវី-ភាវៈ-ភាព : (៤០៨) ? ។
ភារៀង : ពពួកជនជាតិថៃដែលតាំងទីនៅក្នុងដីភូមា, ពពួកក្រុមមនដែរ (បៀកម៉ាន) ។
ភិមឡៃ : (៣៨៣) ? ។
ភិវាត្ត : សររបស់ព្រះរាម ? ។
ភ្ញាន់-ភ្ញដាន់ : (៦៩) ? ។ ផ្កា ? ។
ភ្ញី : ផ្កាដែលមានដើមជាវល្លិ៍ ពាក់ព័ទ្ធ ។
ភ្ញីញារ : ? ១៧២ ។
ភ្ញីទេស : ផ្កាដែលមានដើមជាវល្លិ៍ តែមក

អំពីស្រុកឆ្ងាយ, ប្រទេសឆ្ងាយ ?
ភ្នំនិមិន្ទរ : ? ។

-----------

ម

មហឹង្សា : ក្របី ។
មនីពណ៌នា : កែវដែលមានពណ៌ផ្សេងៗ ។
មហាហង្ស : ផ្កាក្ងោក, ក្ងោកលឿង ។
មហាឬសីកាឡៃ : ព្រះមហាឬសីមួយអង្គ ដែលមានព្រះនាមថា កាឡៃ ។
មហារីក : ជាឈ្មោះយក្សមួយ ដែលកាឡាខ្លួនជាប្រើសមាសមកបញ្ឆោតនាងសីតា ។ - ជាជំងឺមួយប្រភេទ ហៅថា ជំងឺមហារីកដែរ។
មហាជំពូ-ជំពូរាជ : ស្ដេចស្វាមួយអង្គ ។
មហាសរ : ជាឈ្មោះយក្សមួយ ដែលត្រូវអង្គទ ស្ដេចស្វាសម្លាប់ ។
មហាអត្តិកាយ : ជាឈ្មោះក្រុងយក្សមួយអង្គ ដែលត្រូវព្រះលក្សណ៍បាញ់សម្លាប់ ។
មហាក្បាល : ជាឈ្មោះយក្សក្បាលធំ ដែលត្រូវឧសភៈ (ហនុមាន) សម្លាប់ ។
មហារោរព (បា.) : ជាឋាននរកទី៥ ។
មហាដាបនរក (បា.):ជាឋាននរកទី៧ ។
មហាអវិចី (បា.) : ជាឋាននរកដែលជ្រៅជាងគេ ក្នុងឋាននរកទាំង៨ ។
មាលៈ-មាលកៈ (បា.) : កម្រងដែលមានរាងមូល, រង្វង់មូល មាលា ។
មាលមាស : ទម្រង់ កងមាសពេជ្រ ។ សូមអានពាក្យ មាលកៈសាលា (រោងរាងមូលទម្រង់មូល) ទៀតផង ។
មិថិលា : ជានគររបស់បិតានាងសីតា ។
មុត្តា-មុត្តា (បា.) : គុជ, ត្បូងដែលកើតអំពីខ្យង ឬគ្រុំ, គុជខ្យង, ខ្យងដាំ ។
មុលហោ : ? មោហីហោ ? ។
មុខដាច់ : រាងរបស់ផ្ទះ, ផ្ទះមុខដាច់ ។
មុខនាគ : ឈ្មោះផ្លូវចូលអង្គរ ។
មុខរាហ៍ : ហោជាងមានមុខជារាហ៊ូ ។
មុខព្រហ្ម : មុខព្រះព្រហ្មនៅប្រាសាទបាយ័ន, (កវីគាត់បាននាំពួកអំពីប្រាសាទបាយ័នដែរ) ។
មុខរក្ខសៈ : ? ។
មុខរាក្ខខាស : ? ។
មេ ស - មេ្យ ស : បីសាចស្រី, យាយទេព (ទែប), អ្នកតាស្រី ។
មៀមពាក់ព្រៃចរណី : (៣៨២) ? ។
មំសំ : (២៣៩) ? (បា. មំសំ, ឬ មាំងសាំង ?) ។
មករ : ឈ្មោះត្រីសមុទ្រមួយប្រភេទ, ខ.ទ. ហៅថា ទ្រីថ្ករ ឬ ឆ្លាមមករ ។



ម្ដីយ-មុនី : (ម្ដី : រវៀសរវៃ, ប្រញាប់ប្រញាល់) ។

-----------

យ

យន្តកេសរ : (៥២២) ? ។
យន្តស្វាន់ : (៥២៦) ? ។
យន្តលៀងភារ : (៥២៦) ? ។
យន្តគីលេន : (៥២៨) ។
យមរាជ-យោមរាជ : ជាអ្នកកាត់ទោសនៅស្ថានមច្ចុរាជ ។ (ខ.ប.) ប្រើជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។
យាន្តៈ : ? គោម ។
យុគ្គ (បា.) : សម័យ, កាលសម័យ ។ សូមអានពាក្យ : ១. ទ្វារបរមាយុគ្គ, ២.ក្រិត្តិយុគ្គ, ៣.កលិយុគ្គ, ៤.ត្រៃត្រាយុគ ទៀតផង ។
យុគន្ធរ (បា.សំ.) : ឈ្មោះភ្នំដែលទ្រទ្រង់នូវគួព្រះអាទិត្យ និងព្រះច័ន្ទ្រ (ឈ្មោះភ្នំមួយនៃពួកភ្នំសតបរិភណ្ឌ) ប្រដាប់ទ្រទ្រង់ នូវគួ : ទូករទេះ ផងរែក...។
យួនចាស់កែសើន (ឬយួនចាស់តែសើន) : យួនតៃសើន គឺជាក្រុមយួននៅតំបន់ភ្នំភាគខាងលិច ក្រោយអំពីមានសង្គ្រាម បាត់បង់ប្រទេសក៏រត់មកពឹងហ្លួងខ្មែរ។ ហ្លួងខ្មែរ ទទួលអនុញ្ញាតឲ្យស្នាក់នៅ នៅបណ្ដោះអាសន្ន នៅខេត្តព្រះត្រពាំង (កម្ពុជាក្រោម) ។

-----------

រ

រង្គា : (៣៨២) ? ។
រងចាបានមហា : (៤៤២) ? ។
រង្វាស់ : ប្រាំពិលរង្វាស់, នៅទីនេះចាស់ឬរាណប្រើសំដៅ ចំពោះរង្វាស់កម្លាំង, តតាំងកម្លាំង ។ ប្រាំពិលរង្វាស់ : គឺ កងវិស្វកម្មប្រាំពីរក្រុម ។
រក្ខសែន : នាមរបស់យក្ស ។
រតាក-រដាក (ខ.) : សាកត្រាក, រដាច់រដាច, រដាច់រដោច, ជញ្ជាំងផ្ទះរតាក, ខ្នមរដាច់រតាក ។
រន្ទាលល្មៅ : (៤៨០) ? ។
រន្ទា : ឫសី, កូនឈើដែលចងប្រទាក់គ្នាជាថ្នាក់ៗ ដើម្បីឲ្យជាង គុលីឡើងសង់ផ្ទះ, ប្រាសាទ, ព្រះវិហារ, សំណង់ខ្ពស់ៗ ។ (ខ.ទ. រន្ទាល ?) : ពន្លឺចាំង ភ្នែកៗ) ។
រថអស្សយាន : រទេះសេះ ។
រហើត : (៥១១) ? ។
រុង : ធំ, ខ្ពស់, ត្រដែត, ត្រដឹម ។

រុងឆ្មារ : (រុង : ធំ, ខ្ពស់ + ឆ្មារ : ត្នូច), ត្នូច តែយ៉ាងខ្ពស់ ស្រូចទៅលើអាកាស ។

រួហាន (ខ.ថ.) : ផ្លូចជាបីផ្លូច ស្មើរនិង ។

រេចរេក្ខា-រចន៍រេក្ខា : ក្បាច់, ចម្លាក់ផ្សេងៗ ? ។

រោរពនរក (ព.) : នរកឋានទី៤ (ម. ព. មហារោរព ទៀតផង) ។

រៀវឡៀវ : ចង្អេះរាងរៀវ, មានរាង ។

រោក្ខរាក្ខ (ព.) : ឈ្មោះក្រុងយក្ស ។

រោងធម៌ : អង្គរជាឋានសួគ៌, ជាទីប្រជុំអស់ពពួកទេវតា, ជាកន្លែងសាកច្ឆាធម៌ ។

រោងទង : រោងជាង ។

រោងជ្រៀក : រោងឆ្លាក់ថ្ម, ដាប់ថ្ម ឬអារថ្ម, ឈើ...។

រោងក្រឡាបន្ទំ : ទីបន្ទំរបស់ស្តេច ។

រោងរម្យ : ? ១៣៣ (រោងបុណ្យ រោងមហោស្រព) ។

រំចេក : ស្លឹក និងដើមប្រហាក់ប្រហែល និងដើមម្លាស់ដែរ តែស្លឹកវែងជាង, ផ្កាក្រអូប (ត្រូសាររំចេក គឺ រំចាក) ។

រំដួល : ជាផ្កាម្យ៉ាង លំនាំដូចផ្កាក្រវាន់ ទាំងផ្កា ទាំងខ្ចិន, ខ្ចិនក្រអូបសាយភាយ ពេលល្ងាច ។ ស្រុករំដួលក្នុងខែត្រស្វាយរៀង ។

រំដេញមាស : ជាផ្កាម្យ៉ាង ?

រំខើង : ? ។

-----------

**ល**

លតា : វល្លិ៍, ភ្ញីវល្លិ៍ ។

លក : ឈ្លួសឲ្យទៅជាប្រឡាយក្នុងសាច់ឈើ។

ល្អស : ផុះខាត់ ។

លន្វា : សម័យខ្មែរកណ្តាល (ស.ត.ទី ១៦ ដល់ ១៨) ខ្មែរហៅសំដៅជនជាតិ "ហុល្លង់ ឌេស៍" ។

លន្តែ : ផ្កា ? ។

លាយលក្ខណ៍ : ព្រះបាទនៃព្រះពុទ្ធ ។

លៀងភារ : ? ៥០៦ ជាជាតិសាសន៍ក្នុងអំបូរមនខ្មែរដែរ ? ។

លៀងភាលៃ : ? ។

លែង : រួចហើយ, តទៅ, តទៅមុខ ។

លំចង់ : ប្រលិតតូចៗដែលមានពណ៌ផ្សេងៗ។

លំញ៉ង (ខ.), (ដាក់មុខលំញ៉ងចងចិត្ត) : ដាក់មុខចុះដោយសារមានអាឞឹកំបាំង (១៩១, ១៩២, ៥៤១) ? ។

ល្បើក : សូមអានសេចក្តីពន្យល់ខាងដើម ។

ល្អារមាស-លតាមាស : ផ្កាសក់នារី ? ។

ល្អេញល្អៅ : ល្អៗ, ស្រស់ឆើតឆាយ, ស្រស់



ភ្ញុំផាន ។

ល្វេង : ក្រអូបស្រាល, ក្រអូបដាច់ៗ, ក្លិនល្វេង ។

-----------

**វ**

វរោ (សំ.):ប្រសើរ, ឧត្តម, ខ្ពង់ខ្ពស់ ។

វរវង្ស : (វរៈ : ព្រះ+វង្ស, វង្សា : ពូជ), ពូជ, វង្សត្រកូលដ៏ខ្ពង់ខ្ពស់ ។

វរវិរិត : (១៥) ? ។

វិណ្ឌ : ព័ន្ធ, ប្រវ៏ន្ធ, ប្រព័ន្ធ ។

វិនគុក្ខ : ឈ្មោះយក្ស ។

វិវឌ្ឍន៍-វិវល្បន៍ : ការប្រព្រឹត្តិតទៅ, លំដាប់តទៅ, ការរីកចំរើនទៅអនាគត ។

វិវង្កត់-វិនធតក្កៈ : (៤១៤) ? ។

វិស្សកម្ម-វិស្វកម្ម-ពិស្ណុការ-វិស្ណុកម្ម-វិស្ណុការ, (ខ.ទ. : ព្រះពិស្នោការ) : (១១៣), (៤៧២) ជាស្ថាបត្យកររបស់ព្រះឥន្ទ្រ, ជាស្ថាបត្យករប្រចាំស្ថានព្រះឥន្ទ្រ ។

វិហាស្សហារ-វេហា (ព.) : ខ្យល់, មេឃ, អាកាស, លំហ ។

វេស្សវិណ្ណ : ឈ្មោះក្រុងយក្សមួយអង្គ (ក្នុងរឿងរាមកេរ្តិ៍) ។

-----------

**ស**

សក្កៈ-សក្កោ : ព្រះឥន្ទ្រ ។

សសោត្តមំ (ព) : ? ។

សង្ឃាដមហានរក : ឋាននរកទី៣ ។

សញ្ជិតមហានរក : ឋាននរកទី១ ។

សគ្រាស : (១៩៤) ? (សគ្រាស-ស្វរ្យគ្រាស ?) ។

សម្ពាយ : ទាំងឡាយ ។

សម្ភារ : -គ្រឿងផ្សំ, គ្រឿងប្រើប្រាស ។ -ការសាងសន្សំកុសល ។

សរ : ព្រួញ ។ ក្នុងអត្ថបទនេះ ជិះសរ, ទំនងជាសត្វចតុបាទម្យ៉ាង ។

សរសត្តិថ្វា : ? ។

សអន : (៧១) ? ។

សន្ទឹះ : សង្ស័យ ។

សប្ទ-ស័ព្ទ : ពាក្យ ។

សន្ធរា : (សន្ធរៈ, សន្ធរ) : អក្ខរា ឬ សំបុត្រ ? ។

សន្ធាតកាកី : ? ។

សង្កា : សង្ស័ ។

សង្ខយា-សំខ្យា : លាយគ្នា ។

សន្ទឹកកោះព្រៃ : ឈ្មោះព្រៃឈើដ៏ធំដែលព្រះរាមសំណាក់នៅ ។

សហស្សចក្ខា : (ពា.) ដែលមានភ្នែកមួយពាន់, ដែលមានប្រាជ្ញច្រើនអាចដឹងយល់សព្វប្រការ ។

សហស្សធម៌ : ធម៌ ១.០០០, ធម៌ច្រើនអនេក, ធម៌ច្រើនប្រការ ។

សហស្សលៀងភារ : (២៣១) ។

សាធុការំ (ពា.) : ប្រសើរហើយ ។

សារពើស្ងួត្រ : ជ្រុងប្រាសាទ, ជ្រុងៗជាក្បាច់បត់បែននៃសំណង់ ។

សុគ្រីព : ស្តេចស្វា ជាប្អូនរបស់ពាលី ។

សុរិយោ-សុរិយា (សំ.) : ព្រះអាទិត្យ, អាទិទេពនៃព្រះអាទិត្យ ។

សុទស្សន៍សោភ័ណ : ទេសភាពល្អឯក ។

សូកាន : មកអំពីពាក្យ សុរិយកាណ្ឌ-សុរិយកាច្ឆនៈ គឺ កំទេចពេជ្រដែលចាំងពន្លឺថ្ងៃ ។

សួរផិក : (២៤៣) ? ។

សូរបណខា : យក្សស្រីដែលតែងតែតាមចែចង់ព្រះរាម និងព្រះលក្ស្មណ៍ ។

សួរភី : ? ជាផ្កា ។

សួរផិក : (២៤៣) ? ។

ស្ងមែ-សម័យ : ពេលឥឡូវនេះពេល ។

សូរ្យវង្ស : (សូរ្យ-សុរីយ : ព្រះអាទិត្យ + វង្ស : ពូជ, អំបូរ), ពូជអំបូរនៃព្រះអាទិត្យ ។

សេណា : (៤៦២) ? ។

សេដ្ឋោ : ដ៏មានតម្លៃ (ឧ. សេដ្ឋី, សេដ្ឋកិច្ច)។

សៃយាសន៍ : ក្រឡាបន្ទំ ។

សោឡសសួគ៌ (ពា.សំ.) : (សោឡសៈ ដប់ប្រាំមួយ-១៦, សួគ៌ : ស្ថានទេវតា) ។ ឋានទេវតាទាំងដប់ប្រាំមួយ ។

សំជើឞ : សរសើរ, គោរពស្ញប់ស្ញែង ។

ស្បង់កាច់ : (៨១) ?, ផ្កាឈូក (មើលពាក្យ បង្កជ្ឈ ទៀតផង), សត្តបង្កជ្ឈ ។

ស្រឡប់ : អន្ទង់អន្ទោច ។

ស្រមុទ : ស្មុគចិត្ត ។

ស្រលិត : ដើមផ្កាវល្លិ៍ ជាផ្កាចង្កោម មានខ្ទិនក្រអូប ស្រដៀងផ្កាម្លូល, គេប្រើជាបន្ទែយ៉ាងឆ្ងាញ់ពិសារណាស់, ស្ងោរជាមួយសាច់, ស្ងោរកកូរ, ស្ងោរប្រហើរ, ឆា...។

----------

## ហ

ហនុមាន-ពាយុបុត្រ : ស្តេចស្វាស ជាកូនពាយុ (អទិទេពនៃខ្យល់)និងនាងអញ្ជនា ។ ហនុមានជាមេទ័ពរបស់ព្រះរាម ។

ហង្សា, កាវៀង : ពពួកជនជាតិថៃ ដែលតាំងទីនៅក្នុងដីភូមា ពពួកក្រុមមនដែរ ។ ពពួកជនជាតិកាវៀងភាគតិច ដែលរស់តាំងទីនៅ



ក្នុងដីភូមា (បៀកម៉ាន) ។

ហុកកៀន : (១១០) ពពួកចិន ហុកកៀនទាវជីវ ចិនកន្តាំង ។

ហៃ ហុង តាំង ទៀ : (១១០) ពពួកចិនមួយក្រុមតែហៅសំដៅ តាមត្រកូល ត្រកូលហៃ ត្រកូលហុង ត្រកូលតាំង ត្រកូល ទៀ ...។

ហោត្រៃ (ខ.) : បណ្ណាល័យ ។

ហ្វូលចក្ខ-មោលចក្ខៈ ជាឈ្មោះក្រុងយក្សមួយអង្គ ។

----------

## អ

អគ្គោ ឬ អគ្គៈ : (ពា,) ធម្មជាតិដែលដល់នូវភាពប្រសើរ,កំពូល,ខ្ពង់ខ្ពស់,ជាទីបំផុត។

អគ្គោភិនី (ពា.) : សន្ធឹកសន្ធាប់ រាប់ពុំបាន, ច្រើនអនេកអណៈ ។

អង្គទ : ស្តេចស្វាបន្ទាប់ពីហនុមាន ។

អង្គគាល់សហស្សលៀងភា : (២៣១) ។

អញ្ជន់ : (ខ.ទ. កញ្ជន់) ត្រពាំងទឹកតូច, ថ្លុកទឹក, ប្រឡាយទឹក, បឹងតូចៗ ។

អតិកាយ : ជាកូនក្រុងរាពណ៍, និងប្អូនឥន្ទ្រជិត និងជាមេទ័ពរង ។

អប្បមាណ : (ពា.) ដែលស្មានមិនត្រូវដែលរាប់មិនអស់ ។

អនុត្តរីយ : ចង្រៃ, ឧត្បាត ។

អន្ទាមសុរង : ខ្សែទាមអលង្កាសម្រាប់ពាក់នៅក ឬ នៅកសត្វសម្រាប់ទិម ។

អញ្ញា : វុទ្ធា, ព្រៃព្រឹក្សា ។

អសុរៈ-អសុរា : ជាក្រុងយក្ស ។

អសុរភព : ភពដែលគ្មានថ្ងៃ, ខ្វះពន្លឺ, ខ្វះសន្តិសុខ ។ (អាសោរភព ឬ អសុរៈភព : កន្លែងយក្ស, ខ្វះសន្តិសុខ ។

អសុពា : សេះ ។

អភិរម្យ - អភ្ញីរម្យ : សេចក្តីសប្បាយរីករាយដ៏ធំធេង ។

អស្សភណ្ឌ : ? ។

អប្បទ្ធិចន្ទ : ឈ្មោះសររបស់ព្រះរាមបាញ់រំលាយឆ័ត្ររាពណ៍ ។

អាត្តិយលវន្ទៈ : (៣៨៥) ។

អាត្តិយស្បាន់ : (៣៨៥) ។

អាកាសនភី :នភាល័យ, វេហា,មេឃ ។

អំម្ពេញ-អម្ពេញ : ? ។

អំពរ : (៣២៧) ? ។

----------

## ផ្នែកស្រះពេញតួ

### ឥ

ឥទ្ធូវ : ? ។ បពេជ្ជឥទ្ធូវៈ (១៣៧) ? ។
ឥសទ្ធរព្ទ : ? ។
ឥសទ្ធ : ជាឈ្មោះរបស់ក្រុងយក្ស ? ។
ឥន្រ្ទី : សត្វស្លាបក្នុងរឿងអច្ឆរិយ, សត្វស្លាបធំ (មានតែក្នុងរឿងព្រេង, រឿងដំណាល) ។
ឥន្រ្ទជិត : ជាកូនក្រុងរាពណ៍, មេទ័ពយក្សត្រូវស្លាប់ដោយសារលក្សណ៍ នៅចម្បាំងចុងក្រោយ ។ យក្សមួយឈ្មោះព្រហស្តជាអ្នកបរ រាជរថរបស់ឥន្រ្ទជិត ។

----------

### ឯ

ឯក : មួយ, លេខ១, ប្រសើរលើសគេ ។
ឯកបញ្ចោ : សូមពិនិត្យមើលអំពីការសិក្សានៅក្នុងអត្ថបទខាងលើនេះ ។

### ឰ

ឰយុទ្យា-អយុទ្ធយា-អយុទ្ធាៈគ្មានសង្គ្រាម។

----------

### ឱ

ឱស្ឋ : មាត់ (រាជស័ព្ទ) ។
ឱភាសៈ (សំ.) : ? ៣៨២(ជិះឱភាស ?)
ឱសភៈ : -គោរបស់ព្រះ ឬ របស់ព្រះមហាក្សត្រិយ៍, ពពួកក្រុមចតុបាទ, -ជាស្តេចស្វាមួយដែលជាមេទ័ពរបស់ព្រះ រាម ។
ឱទា (-ឱទរ ?) : ? ៤៦១ ។

---------------

* លេខក្នុងនេះ ជាលេខនៃវគ្គកំណាព្យ ។



# ព្រឹត្តិការណ៍ខ្លះៗក្នុងតំបន់អាស៊ី និងនៅកម្ពុជា ជុំវិញសម័យកាល និពន្ធរឿងល្បើកអង្គរវត្ត សតវត្សទី១៦ និង ទី១៧

ដោយ សុខា ធួម

## នៅសតវត្សទី១៦

១-សៀវភៅប្រវត្តិសាស្ត្រចិនឈ្មោះ "ការចេះចាំជាទូទៅក្នុងប្រវត្តិសាស្ត្រចិន"[1] (Connaissance générale en Histoire chinoise) គេបានកត់ត្រាទុកថា "លោកហៃ រ៉ី (ឆ្នាំ១៥១៤-១៥៨៧) ជាអ្នកច្បាប់តែមួយគត់ ក្នុងប្រវត្តិសាស្ត្រចិន ដែលធ្វើការសុចរិតឥតពុករលួយរហូតដល់អ្នកស្រុកដាក់ឈ្មោះឲ្យថា លោកហៃ រ៉ី មេឃស្រឡះ" (ទំព័រ ១៤៩) ។

២-សៀវភៅប្រវត្តិសាស្ត្រថៃឈ្មោះ "មហារាជ និង វីរៈស្ត្រីថៃ[2] បានចារទុកនៅទំព័រទី១៩ថា : "ស្តេចនរេសួរ បានប្រសូតនៅគ.ស.១៥៥១ គឺព.ស.២០៩៤ នៅខែត្រព្រះវិស្ណុលោក នាក្រុងសុខោទ័យ ។ ស្តេចនរេសួរ ជាបុត្ររបស់ព្រះមហាធម្មរាជាធិរាជ និងព្រះវិសុទ្ធក្សត្រី ។ ស្តេចនរេសួរមានបងស្រីព្រះនាម សុភ័ណកល្យាណី និងប្អូនប្រុសព្រះនាមឯកទស្សន៍ ។ គឺនរេសួរនេះឯងហើយ ដែលមកវាយបន្ទាយលង្វែក ដឹកជញ្ជូនព្រះគោ ព្រះកែវ មាស ប្រាក់ និងសម្បត្តិវប្បធម៌ខ្មែរ ព្រមទាំងកៀរយកមនុស្សខ្មែរទៅស្រុកសៀមជាច្រើនផង" ។

៣-សៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោកត្រឹង ងា[3] បានសរសេរថា "នៅឆ្នាំ១៥១៥ ព្រះចន្ទរាជា ដែលបានចូលសុំជ្រកកោននៅក្រុងស្រីអយុធ្យានោះ ដោយបានដឹងថា ព្រះស្រីសុគន្ធបទ ត្រូវស្តេចកនធ្វើគតហើយ ក៏ធ្វើកិច្ចកល់សុំលាស្តេចសៀមថា និងនាំទ័ពទៅទាក់ជីវិតនៅឯស្រុកខ្មែរ ។

1. សៀវភៅប្រវត្តិសាស្ត្រឈ្មោះ "ការចេះដឹងទូទៅក្នុងប្រវត្តិសាស្ត្រចិន" (Connaissance générale en histoire chinoise) បោះពុម្ពដោយការិយាល័យនៃក្រុមប្រឹក្សាអន្តរជាតិខាងភាសាចិន (The Office of Chinese language conseil International) នៅ ខែវិច្ឆិកា ឆ្នាំ២០០៦ ។

2. សៀវភៅប្រវត្តិសាស្ត្រថៃឈ្មោះ "មហារាជ និងវីរៈស្ត្រីថៃ" សរសេរដោយលោក សំនៀង វៀនរាជវ័ជតៈ, បោះពុម្ពដោយរោងពុម្ពអក្សរវឌ្ឍន នៅព.ស.២៥៤៣ គ.ស.២០០០, ។

3. ប្រវត្តិសាស្ត្រខ្មែរ ភាគទី២ របស់លោកត្រឹង ងា បោះពុម្ពដោយវិទ្យាស្ថានខ្មែរ នៅឆ្នាំ១៩៧៤, សូមអញ្ជើញអាននៅត្រង់ទំព័រ ១៤, ១៥, ១៦, ១៩ ។



ព្រះអង្គបានមកជួបនុកញ៉ា ពេជ[4] នៅខែត្រពោធិសាត់ ក៏ព្រួតដៃគ្នាយ៉ាងមុតមាំលើកទ័ពទៅវាយស្តេចកន (ស្រីរាជា) យ៉ាងស្វិតស្វាញអស់រយៈពេល៩ឆ្នាំ គឺពីឆ្នាំ១៥១៦ ដល់ ១៥២៥ ទើបសម្លាប់ស្តេចកនបាន នៅបន្ទាយស្រឡាប់ពីជ័យព្រៃនគរចន្ទោះ បាភ្នំ និង ស្វាយជ្រុំ" ។

៤-សៀវភៅប្រវត្តិសាស្ត្រខ្មែរ សរសេរដោយលោកដូហ្វាំង ម៉ឺនីញេរ[5] បានកត់ត្រាបញ្ជាក់ថា "នៅឆ្នាំ១៥២៥ផងដែលនេះ ដោយព្រះអង្គចន្ទពុំព្រមលើកសួយសារអាករ ទៅថ្វាយស្តេចសៀមៗ ក៏ឲ្យលើកទ័ពមកវាយភូមិភាគខាងត្បូងអង្គរ ប៉ុន្តែទ័ពព្រះអង្គចន្ទរាជា វាយពង្រាបយកជ័យជំនះបាន ហើយដាក់ឈ្មោះភូមិភាគនោះថា ខេត្តសៀមរាប តាំងពីឆ្នាំ១៥២៥នោះមក" ។

៥-សៀវភៅប្រវត្តិសាស្ត្ររបស់លោកត្រឹង ងា[6] បានសរសេរទៀតថា "ព្រះចន្ទរាជា ជាក្សត្រិយ៍អ្នករំដោះ (ទំព័រ ៧៨-៨០-៨២) ការពារទឹកដី, ឧបត្ថម្ភព្រះពុទ្ធសាសនា, ពង្រីកអក្សរសាស្ត្រ និងពង្រីកសេដ្ឋកិច្ច ។
ទ្រង់បានប្រមូលពពួកអ្នកប្រាជ្ញមកជារាជបណ្ឌិត ពីគ្រប់ទិសទីជាគ្រឹះនៃចំណេះវិជ្ជាជាតិ ។ ទ្រង់បានពង្រឹងរបបគ្រប់គ្រងដោយបង្កើតស្តេចត្រាញ់៥អង្គគឺ ៖

១-នៅខេត្តភ្នំសន្ទុក (អាសន្នទុក្ខ),
២-នៅខេត្តពោធិសាត់,
៣-នៅខេត្តស្វាយជ្រុំ,
៤-នៅខេត្តបាភ្នំ,
៥-នៅខេត្តទ្រាំង ។

4. នុកញ៉ា ពេជ នេះហើយ ក្រោយមកក្លាយជាអ្នកតាឃ្លាំងមឿង ទៅកែនទ័ពបីសាចមកជួយព្រះច័ន្ទរាជាទាល់តែវាយឈ្នះស្តេចកន ។

5. សៀវភៅប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជារបស់លោក អា. ដូហ្វាំង ម៉ឺនីញេ (A. Dauphin Menier), បោះពុម្ពលើទី២ ដោយក្រុមបញ្ញាធិការនៃសាកលវិទ្យាល័យ ប្រទេសបារាំង (Edition : Presses Universitaires de France នៅឆ្នាំ ១៩៦៨ ។

6. សូមអានសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោក ត្រឹង ងា ។

ព្រះអង្គចន្ទរាជា ទ្រង់សុគតនៅឆ្នាំ១៥៦៦ ។ ព្រះអដ្ឋិធាតុដំកល់នៅព្រះចេតីយ៍ភ្នំព្រះរាជទ្រព្យ "ក្រុងឧត្តុង្គ" ។

៦-ក្នុងន័យវប្បធម៌ ប្រវត្តិសាស្ត្រសរសេរដោយលោកត្រឹង ងា [7] ត្រង់ទំព័រ១៥ និង ៥១ បានថា ៖

នៅឆ្នាំ១៥១២ ស្តេចកន (ស្រីរាជា) បានឈ្នះព្រះស្រីសុគន្ធបទ នៅបន្ទាយស្ទឹងសែន ហើយគិតរៀបពិធីព្រាហ្មាភិសេក (អភិសេកក្រោយចម្បាំង ប៉ុន្តែ រកគ្រឿងបញ្ចកកុធភ័ណ្ឌមិនឃើញ ក៏រៀបចំពិធីដោយខ្វះប្រដាប់ប្រដានោះទៅ ។ ថាដោយសារឥសីភ័ទ្រ បានយកទៅលាក់ទុកនៅក្នុងរន្ធដើមចំបក់ឯក្នុងព្រៃ ទើបរកមិនឃើញបញ្ចកកុធភ័ណ្ឌនោះ ។

៧-សៀវភៅលោកត្រឹង ងា ផងដែល, [8] បានសរសេរត្រង់ទំព័រ៥១ថា ៖ រីឯព្រះចន្ទរាជា, តាមសំណូមពរពីព្រះរាជវង្សានុវង្ស និងនាហ្មឺនសព្វមុខមន្ត្រី ព្រមទាំងប្រជារាស្ត្រផង ទ្រង់ក៏ព្រមទទួលពិធីសង្គ្រាមាភិសេក (អភិសេកក្នុងពេលចម្បាំង) នៅគ.ស.១៥១៦ ដោយសន្យាថា និងទទួលព្រះរាជាភិសេកសោយរាជ្យនៅពេលចប់សង្គ្រាមនិងរកបញ្ចកកុធភ័ណ្ឌឃើញវិញ។ ដោយព្រះអង្គជាក្សត្រិយ៍ ទសពិធរាជធម៌ នៅមុនដឹតរៀបចំពិធីរាជាភិសេកឡើងសោយរាជ្យ មានក្រឡាពាសម្នាក់យល់សុប្តិនឃើញថា ត្រូវទៅយកបញ្ចកកុធភ័ណ្ឌពីក្នុងរូងដើមចំបក់ឯក្នុងព្រៃមករៀបចំពិធីរាជាភិសេក ។

បញ្ចកកុធភ័ណ្ឌគឺ ៖

១-ព្រះមកុដ្ឋរាជ,

២-ព្រះវាលវិជនី : ផ្លិតស្លាបសត្វពណ៌ស,

៣-ព្រះខាន់រាជ,

៤-ព្រះស្វេតឆ័ត្រ,

៥-ព្រះសុពណ្ណ៌បាទ ឬ ព្រះសុវណ្ណបាទុកា ។

7. សូមអានសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោក ត្រឹង ងា ។

8. សូមអានសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោក ត្រឹង ងា ។



៨-សៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោក ដាវិឌ ឆាណ្ឌល័រ [9] (Devid Chandler), បានចារនៅទំព័រ៨៧ថា ៖

ក-នៅចន្លោះឆ្នាំ១៥១២ និង ១៥១៥ លោកតុប ប៉េរ៉េ (Tom Pérès) ជនជាតិព័រទុយគេស៍ បានសរសេរថា : លោកចាំទ្រី (អាចារ្យកាតូលិក) គ្គាស្ប៉ា ដឺ គ្រុយូ មានការកោតសរសើរស្ងប់ស្ងែងខ្លាំងណាស់ នូវសាមគ្គីភាពរបស់ប្រជារាស្ត្រខ្មែរ ដែលមិនងាយនរណាជ្រៀតជ្រែកបំបែកបាននេះម្យ៉ាង" ។

ម្យ៉ាងទៀតលោក ចាំទ្រី គ្គាស្ប៉ា ដឺ គ្រុស្ស បានសរសេរទៀតថា "ព្រះសង្ឃមានចំនួនច្រើនជាងមួយភាគបីនៃចំនួនបុរសខ្មែរ ដែលកំពុងពេញវ័យនៅកម្ពុជា ។

ខ-លោកចាំទ្រី បញ្ជាក់ទៀតថា : គ្មាននរណាហ៊ានធ្វើអ្វីផ្អយនិងព្រះសង្ឃទាំងនោះឡើយ ។ មានពេលខ្វះ ខណៈដែលខ្ញុំកំពុងទេសនា កំពុងមានមនុស្សមកជួបជុំជាច្រើន បើសិនជាមានភិក្ខុមួយអង្គណានិមន្តមក ហើយមានថេរដីកាថា : "អ្វីដែលលោកនេះនិយាយក៏ល្អម្យ៉ាង ក៏ប៉ុន្តែធម៌របស់យើងល្អជាង" ក៏គេដើរចេញពីខ្ញុំអស់រលីង ។ បើតាមសំណេរទាំងនេះ យើងអាចវិនិច្ឆ័យបានថាព្រះពុទ្ធសាសនា និងព្រះសង្ឃនាសម័យនោះ (ស.វ.ទី១៦) ពិតមែនតែប្រទេសមានភាពវឹកវរ ក៏នៅមានកំឡាំងខ្លាំងក្លាជាធម្មតា ។

៩-តាមសៀវភៅប្រវត្តិសាស្ត្រលាវ [10] យើងបានដឹងថា [11] នៅប្រទេសលាវក្នុងកំឡុងសតវត្សទី ១៦ និង ១៧ មានការវឹកវរ ច្របូកច្របល់ ប្រហាក់ប្រហែលគ្នានិងស្រុកខ្មែរដែរ គឺចេះតែមានចម្បាំងរវាងសៀម, ភូមា និង លាវ វិលទៅវិលមក មិនចេះចប់ ។

នៅឆ្នាំ១៥៧៥ភូមាលើកទ័ពមកវាយក្រុងវៀងច័ន្ទ បណ្តេញព្រះចៅ ថាំមិក្ករាត (ធម្មិករាជ) ឲ្យចុះពីរាជ្យបល្ល័ង្ក ចំណែកឯ ចាវ សែ ឬ សេដ្ឋាធិរាត ដែលជាស្តេចធំសោយរាជ្យនៅហ្លួងព្រះបង

9. ប្រវត្តិសាស្ត្រខ្មែររបស់ ដាវិឌ ឆាណ្ឌល័រ (Devid Chandler), បោះពុម្ពផ្សាយលើកទី២ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។

10. ប្រវត្តិសាស្ត្រលាវ (Histoire du Pays Laos) សរសេរដោយលោក សាវ៉ែង ភិនិត, ភូវេន ស៊ុកអាលុន និង ភាំន់នីងា ចងច័ន្ទ, បោះពុម្ពដោយបណ្ណាធិការ អារម៉ាត្តង់ ប៉ារីស ឆ្នាំ១៩៩៩ ។

11. នេះជាយោបល់របស់អ្នកនិពន្ធដោយធ្វើសំយោគក្រោយពីបានអានអត្ថបទ ។

ចុះមកជួយមិនទាន់ ។

១០-តាមសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់លោកត្រឹង ងា ភាគទី២ [12] ត្រង់ទំព័រ១៥០បាន ចារថា "នៅគ.ស.១៥៧២ ស្តេចលាវឥតរលាន ជាងទ្រង់ត្រាស់បញ្ជាឲ្យនាម៉ឺន២នាក់ និងពល ១០០០នាក់ (ចុះទូកផង ជិះដំរីតាមផ្លូវគោកផង) មកបបួលខ្មែរប្រជល់ដំរីដាក់នគរ ។ គឺថាបើ ដំរីនគរណាចាញ់ត្រូវចំណុះនគរម្ខាងទៀតដែលមានដំរីឈ្នះ ។ កាលណោះព្រះបាទបរមរាជា ទី៤ គង់នៅកំពង់ក្រសាំងនាតំបន់អង្គរ ព្រះអង្គយល់ព្រមចំពោះសំណើររបស់លាវ ។ ការប្រជល់ ដំរីប្រព្រឹត្តិទៅនៅស្បែរក្រុងលង្វែក ។ ដោយសារលាវខឹងខ្លាំងពេក ក៏លើកទ័ពជើងទឹកជើងគោក មកវាយខ្មែរ, តែត្រូវខ្មែរចាប់ពលលាវបានជាច្រើន, យក៨០០នាក់ទៅដាក់នៅបាភ្នំ ហើយ៥០០ នាក់ដាក់នៅស្បែរវត្តភ្នំផ្នូនពេញ, ភូមិនេះខ្មែរហៅភូមិលាវបាក់ទូក ហើយសព្វថ្ងៃមាននៅសល់ តែលាសាបាក់ទូក ។

## នៅសតវត្សទី១៧

១-សៀវភៅប្រវត្តិសាស្ត្រចិនឈ្មោះថា "ការចេះចាំទូទៅក្នុងប្រវត្តិសាស្ត្រចិន" [13] ដែល គេបានសរសេរនៅទំព័រ១៥១ចារថា : នៅគ.ស.១៦៤៤ (ក្នុងខែតុលា), ក្នុងរាជវង្សឈីង (Dynastie du Qing), ស្តេចចក្រ ស៊ុន ជី បានលើករាជធានីពីក្រុង សេង ជិង ទៅ ក្រុង ពៃ ជិង (Peking) ម្តងទៀត ។

២-តាមសៀវភៅដដែល, [14] នៅទំព័រ១៥៤ គេមានសរសេរថា ជនជាតិហុល្លង់ដេស៍ បាន ចូលទៅផ្សាយសាសនា និងត្រួតត្រាកោះតៃវ៉ាន់បន្តិចម្តងៗ ហើយរវាងឆ្នាំ១៦៦០, ប៉ុន្តែ លោក មេទ័ពចិនម្នាក់ឈ្មោះ ចេង ឆេង គង់បានស្ម័គ្រចិត្តនាំទ័ពចិន ចូលទៅជួយរាស្ត្រតៃវ៉ាន់ នៅឆ្នាំ ១៦៦១, ហើយបានបណ្តេញពួកហុល្លង់ដេស៍ចេញអស់ ពីកោះ នៅឆ្នាំ១៦៦២ ។

12. សូមអានប្រវត្តិសាស្ត្រខ្មែរ ភាគទី២ របស់លោកត្រឹង ងា ។
13. សូមអានសៀវភៅប្រវត្តិសាស្ត្រឈ្មោះ "ការចេះដឹងទូទៅក្នុងប្រវត្តិសាស្ត្រចិន" ។
14. សូមអានសៀវភៅប្រវត្តិសាស្ត្រឈ្មោះ "ការចេះដឹងទូទៅក្នុងប្រវត្តិសាស្ត្រចិន" ។



៣-សៀវភៅប្រវត្តិសាស្ត្រខ្មែរ សរសេរដោយលោកដាវីឌ ឆាណ្ឌល័រ, [15] ត្រង់ទំព័រ៩២ បាន ចារថា : "បន្ទាប់ពីបាត់បង់បន្ទាយលង្វែក (១៥៩៣) ទៅហើយក្តី, ហើយទោះបីមានភាព វំលើបរំផ្លូលខ្លះក្នុងរាជវង្សក្តី ក៏ខ្មែរបានរៀបចំក្រុងឧត្តុង្គ ឲ្យមានសកម្មភាពជំនួញជាតិ និងអន្តរ ជាតិបន្តទៅទៀតជានិច្ច ។

ឧទាហរណ៍ដូចជាលោក ហ៊ាំទ្រី ផ្លាស្យ៉ា ឌី គ្រុស្ស (អាចារ្យកាតូលិក) បានឃើញនិងរៀបរាប់ថា : មានមាស, មានប្រាក់ (គ្រឿង) ស្ពាង, ក្រណាត់សូត, ក្រណាត់អំបោះ, កំញាញ, ម្រ័ក្សណ៍, ភ្លុកដំរី, អង្ករ, ផ្លែឈើ... ។ ដំរី, ក្របី, រមាស...។

ដូច្នេះ នាំឲ្យយើងគិតឃើញតទៅទៀតថា :

ប្រសិនបើសកម្មភាពសេដ្ឋកិច្ចនៅមាន នៅរស់រវើកដូច្នោះ សកម្មភាពសង្គមកិច្ចនេះ ក៏បង្ហាញ ប្រាប់យើងអំពីសកម្មភាពសាសនា និងសកម្មភាពវប្បធម៌ ដែលត្រូវតែនៅរស់រវើកផងដែរ ដូច លោក ហ៊ាំទ្រី ផ្លាស្យ៉ា ឌី គ្រុយ្ស បានសរសេរកោតសរសើរនៅឆ្នាំ១៥១៥ ខាងលើស្រាប់ហើយ ក្នុងនោះមុនបន្តិច ឬ ក្រោយបន្តិច ក៏មានលោកការីយ៉ាង តាត ម្នាក់ទៀត ដែលបានសរសេរ កំណាព្យរឿងល្បើកអង្គរវត្តនេះ ។

៤-នៅប្រទេសលាវ សៀវភៅប្រវត្តិសាស្ត្រប្រទេសលាវ, [16] ចែងថា : ក្នុងរាជព្រះចៅសូលី ញ៉ា វង្សា (សុរិយវង្សា) ពីឆ្នាំ១៦៣៧ ដល់ ១៦៩៤ មានពួកហុល្លង់ដេស៍ ទាំងខាងជំនួញ និង ទាំងខាងសាសនា បានចូលមកដល់ប្រទេសលាវ ដូចនៅកម្ពុជាដែរ ។

យើងដកស្រង់ចំណារនេះ មកគ្រាន់តែជាការប្រៀបធៀបថា ក្នុងកាលបរិច្ឆេទប្រហាក់ប្រហែល គ្នានោះ នៅភូមិភាគអាស៊ីមាន កម្ពុជា, ចិន, លាវ ជាដើម មានពួកអឺរុបចូលដល់ដូចគ្នា ។ អញ្ចឹងក៏ជាការអាចរំខានដល់ស្ថានភាពវប្បធម៌របស់សាម៉ីស្រុកទាំងនោះផងដែរ ។

៥-លោកកែវ ប៊ុនធឿន បានសរសេរសៀវភៅឈ្មោះ "ប្រវត្តិខ្លះលើព្រំដែនខ្មែរខាងកើត"

15. សូមអានប្រវត្តិសាស្ត្រខ្មែរ របស់ដាវីឌ ឆាណ្ឌល័រ (Devid Chandler) ។
16. ប្រវត្តិសាស្ត្រលាវ (Histoire du Pays Laos) សរសេរដោយលោក សាវ៉ាង ភិធិត, ភូមើន ស៊ុកអាលុន និង វ៉ាន់ឌីងា ចងច័ន្ទ, បោះពុម្ពដោយបណ្ណាធិការ អារម៉ាត្តង់ ប៉ារីស ឆ្នាំ១៩៩៩ ។

[១៧] (រវាំងគ.ស.១៦១៨) ត្រង់ទំព័រលេខ៥៦-៥៧-៥៨ ស្តីអំពីប្រវត្តិឃ្មុនចងដៃ ។ មួយវគ្គទៀត ត្រង់ទំព័រ៥៧ លោកបានចារថា "ស្តេចជ័យជេដ្ឋាទី២ បានទទួលជំនួនអំពីឪពុកក្មេក សៃ វ្វង, នៅថ្ងៃរៀបការនូវនារីឃ្មុន៥០០ និង បុរស៥០០ ដែលផង្គែក្បត្រីឃ្មុន តាមសំពៅ១៥គ្រឿង"... នេះបង្ហាញឲ្យឃើញថា នៅសតវត្សទី១៧ យើងបានជួបប្រទះទាំងរឿងល្អទាំងរឿងអាក្រក់ ។ ប៉ុន្តែក្នុងវិស័យអក្សរសាស្ត្រ, វប្បធម៌, ពាណិជ្ជកម្ម និងសេដ្ឋកិច្ច ខ្មែរយើងនៅពេលនោះ ក៏នៅតែមានការរីកដុះដាលជានិច្ច ដូចលោក ដាវិឌ ឆាណ្ឌល័រ បានសរសេរ (ក្នុងសៀវភៅប្រវត្តិសាស្ត្រខ្មែររបស់គាត់ផងែល) ។

**៦-លោកដាវិឌ ឆាណ្ឌល័រ** [១៨] បានសរសេរជាច្រើនទៀតនៅទំព័រ៩៤ ស្តីអំពីគុណដំឡៃ និងគុណសម្បត្តិនៅប្រទេសកម្ពុជា ក្នុងសតវត្សទី១៧ ៖

នៅបន្ទាត់ទី១៥-១៦-១៧ លោកបានកត់ត្រាថា "ប្រពៃណីអក្សរសាស្ត្ររបស់វរៈជនខ្មែរ ដូចដែលមានក្នុងរឿងរាមកេ្តរ៌ ដែលនិទានបែបខ្មែរនូវរឿងរាមាយណៈរបស់ឥណ្ឌា និងក្នុងសិលាចារឹកនគរវត្ត ព្រមទាំងស្នាដៃផ្សេងៗទៀត មានការរីកចំរើននៅសតវត្សទី១៧ យ៉ាងខ្លាំងក្លាជាងនៅសតវត្សទី១៩"...។

**៧-តមកទៀត លោកដាវិឌ ឆាណ្ឌល័រ,** [១៩] បានដកស្រង់នូវមតិរបស់លោកស្រីបណ្ឌិត ពៅ សារស មកបញ្ជាក់យ៉ាងវែងអំពីការរីកចំរើនផ្នែកវប្បធម៌ក្នុងសតវត្សទី១៧ ដោយមានកថាខ័ណ្ឌមួយនោះ លោកបានសរសេរតាំងពីបន្ទាត់ទី២៧ ដល់បន្ទាត់ទី៣១ ដោយធ្វើការកោតសរសើរថា "លោកស្រីបណ្ឌិត ពៅ សារស បានយល់ឃើញថា ដំឡៃទាំងនោះមានទំនាក់ទំនងជាមួយនិងសញ្ញាណខាងពុទ្ធសាសនា ដែលគេប្រៀនប្រដៅតៗគ្នាពីមាត់មួយ ទៅមាត់មួយ ដូចដែលមានរក្សាទុកក្នុងច្បាប់កូនចៅទាំងឡាយ ដែលសិស្សានុសិស្សខ្មែរ នៅទន្ទេញចាំមាត់រហូតមកដល់

17. ប្រវត្តិខ្លះលើព្រំដែនខ្មែរខាងកើត របស់លោក កែវ ប៊ុនធឿន, បោះពុម្ពលើកទី១ ដោយបណ្ណាធិការអប្សរា នៅក្រុងម៉ុងរេអាល, កាណាដា ឆ្នាំ១៩៨៦ ។

18. សូមអានប្រវត្តិសាស្ត្រខ្មែររបស់ដាវិឌ ឆាណ្ឌល័រ (Devid Chandler) ។

19. សូមអានប្រវត្តិសាស្ត្រខ្មែររបស់ដាវិឌ ឆាណ្ឌល័រ (Devid Chandler) ។



សព្វថ្ងៃនេះ ។ ដូច្នេះ លោកស្រីបណ្ឌិត ពៅ សារស បានយល់ឃើញថា ប្រទេសកម្ពុជាក្នុងសតវត្សទី១៧, ជាប្រទេសមួយដែលរស់នៅស្របតាមក្រមច្បាប់ត្រឹមត្រូវ ដែលក្រោយមកបានធ្លាក់ចុះខ្សោយ ហើយត្រូវគេបំពារបំពាន ឬ បំភ្លេចចោល ។

តាមឧត្តមគតិបូរាណខ្មែរ, ទីក្រុងធំ ឬ បុរី ដែលមានព្រះមហាក្សត្រគង់ប្រថាប់នៅ (រាជវាំង) ជាអតិសុខុមលោកមួយ ឬ ជាស្ថានសួគ៌មួយ (របស់មនុស្ស) រហូតតាំងពីបូរាណកាលមក ។ ដូច្នេះ បានជាយើងឃើញមកដល់សព្វថ្ងៃ នៅព្រះរាជវាំងចតុមុខ (ភ្នំពេញ) មានឈ្មោះស្ថាបត្យកម្មផ្សេងៗ សុទ្ធតែរបៀបស្ថានសួគ៌ ត្រៃត្រឹង្សា ដូចជា :

ព្រះមហាប្រាសាទខេមរិន្ទ, ព្រះមហាប្រាសាទវិហារសួគ៌, ព្រះទីនាំងច័ន្ទ្រឆាយា, ព្រះទីនាំងទេវាវិនិច្ឆ័យ ឬ ព្រះទីនាំងពេជ្រយន្ត....

គឺតាមគំនិតអតិសុខុមលោក (Microcosme) នេះឯងហើយ ដែលពេលទុក្ខសោក ក្នុងពេលចុះអន់ខ្សោយ ដោយចំបាំងរាំងជល វិចវិល ទាំងប្រទេស ទាំងរាជធានី ទាំងពលរដ្ឋ ទាំងធនធាន ទាំងសម្បត្តិវប្បធម៌ លោកកវីចាំង តាត ដែលបានទៅឃើញមហាប្រាសាទនគរវត្ត [២០] ដែលត្រូវបោះបង់ចោលក្នុងព្រៃព្រឹក្សា នាំឲ្យលោកមានមនោសញ្ចេតនា គោរពបូជា ស្រឡាញ់ កោតខ្លាច រួញរា សោកស្តាយ ស្រណោះ អាឡោះអាល័យលាយគ្នា ហាក់មិនគួរជឿថា ជាស្នាដៃនៃបុព្វបុរសដូនតាខ្មែរ ដ៏ខ្លាំងពូកែបានសាងទុកមក លោកកវីនឹកភ្នកមានពន្លកឧត្តមគតិ សរសេរចងក្រង ចារបញ្ជាក់ជាកំណាព្យរឿងល្បើកអង្គរវត្តនេះឡើង ក្នុងបំណងចង់កោតសរសើរស្នាដៃថែមទាំងលើកដំកើងមហាបុព្វបុរសរបស់យើង ឲ្យបានស្ថិតនៅខ្ពង់ខ្ពស់ រុងរឿង ទៅតាមឧត្តមគតិវប្បធម៌បូរាណ ដោយលោកបានចាប់ផ្តើមលើករាជធានីអង្គរ ឲ្យទៅជាស្ថានសួគ៌, ព្រះបាទសូរិយោវរ្ម័ទេវ ទៅជាព្រះឥន្ទ្រាធិរាជលើកអង្គវិស្វកម្ម ដ៏អង់អាចទៅជាព្រះវិស្វកម្មទេវបុត្រ ហែរហមអមអង្គដោយវិស្វករបរិវា និងលើកដម្កើងពលរដ្ឋ ខេមរី ខេមរា អ្នកទទួលមរតកដ៏មានដំឡៃថ្លៃថ្លា. ឲ្យទៅជាព្រះកេតុមាលា បុត្រារបស់ព្រះឥន្ទ្រាធិរាជតែម្តង ឲ្យបានសក្តិសមនិងវត្ថុបំណង ដែលបុព្វបុរសទាំងអស់បានប្រាថ្នាកសាងតទៅ ។

២០. ដ៏ធំស្កឹមស្កៃរុងរឿងដោយក្បូរក្បាច់រចនាសាងដោយថ្មាំងសីលា មានរាងជ្រុងមូលបញ្ចូលចំរុះគ្នាកកើតជាមហាប្រាសាទគុហា ។

ឲ្យថ្លៃ យើងខ្មែរជំនាន់ក្រោយ មិនគប្បីបណ្តោយអារម្មណ៍ឲ្យជឿងងល់តទៅទៀតទេ ថាហេតុអ្វីបានជាប្រវត្តិសាស្ត្របានចារច្បាស់ថា ព្រះករុណាព្រះបាទសុរិយាវម៌្មទេវាទី២ បានសាងប្រាសាទនគរវត្ត ហើយស្រាប់តែកវីយ៉ាង តាត បានចារចែងចាត់ថា ជាស្នាដៃព្រះហស្តព្រះពិស្ណុការបានត្រូវបញ្ជាដោយព្រះឥន្ទ្រា ចុះមកសាងប្រាសាទនេះ ថ្វាយព្រះកេតុមាលាជាព្រះរាជបុត្រទៅវិញ ។

នេះគឺជាស្នាដៃវប្បធម៌ និងអក្សរសាស្ត្រ ដែលអ្នកកវីបានលើកទាំងគំនិត ទាំងល្បះ ទុកបង្ហាញឲ្យយើងខ្មែរឃើញច្បាស់នូវក្បួរក្បាច់វប្បធម៌អក្សរសាស្ត្រនៃសតវត្សមុន ៕



ស្នាដៃនេះត្រូវបានផ្តួចផ្តើមដោយសមាគមបច្ចេកទេសការរួមជាក្រុម

**សុខា ឆ្នូម**

និពន្ធលំនាំដើម, ប្រវត្តិសង្ខេប, ស្រង់បទានុក្រម, អ្នកទំនាក់ទំនង

**ឃាម ណាយលី**

និពន្ធលំនាំដើម, ចម្លងជាអក្ខរាវិរុទ្ធខ្មែរទំនើប, អ្នកទំនាក់ទំនង និងវាយអត្ថបទបញ្ចូលក្នុងអង្គុលីទស្សន៍ ព្រមទាំងរៀបចំក្រងទំព័រ

**ហៃ ចន្ណាត**

អ្នកស្ទេន, សំអាតឯកសារដើម, វាយអត្ថបទបញ្ចូលក្នុងអង្គុលីទស្សន៍, ព្រមទាំងរៀបចំក្រងទំព័រ ។